**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

-សាលក្រមព្រហ្មទណ្ឌលេខ: ២៩ "ខ១"

ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩

-សំណុំរឿងព្រហ្មទណ្ឌលេខ: ១៧៥

ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨

-សំណុំរឿងស៊ើបសួរលេខ: ៥១៤

ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨

-សំណុំរឿងជំនុំជម្រះលេខ: ៥០៧

ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩

# តា ម នា ម ប្រ ជា រា ស្ត្រ ខ្មែ រ

## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង២:៣០ រសៀល នៅសាលសវនាការលេខ: ១B ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលដំបូងខេត្តសៀមរាប

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តសៀមរាប។

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប។

ដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខ: ១៧៥ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលមាន:

ឈ្មោះ [redacted]ទ្រិក អាល់បឺតប្រុន (Patrick Albert Pronk) ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិហូឡង់ កាន់អតីតនាយករងសណ្ឋាគារ Victoria Angkor Resort & spa ទីលំនៅបច្ចុប្បន្ន[redacted] ខេត្តសៀមរាប លិខិតឆ្លងដែនលេខ [redacted] ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៥ (ក្រៅឃុំ)។

ត្រូវជាប់ចោទពីបទ: សុំផ្តល់ឯកសារដោយទុច្ចរិត ប្រព្រឹត្តនៅខេត្តសៀមរាប កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៦៣២ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុងជេរ [redacted] Gontier) ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិបារាំង ទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តសៀមរាប។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរលេខ: ១៧៥ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៤២៤ អ.យ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ២៤១០ ពស.ព្រស "ឈ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប។

**អង្គហេតុកើតមានដូចតទៅ**

ឈ្មោះ [redacted] Albert Pronk ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិហូឡង់ ធ្លាប់ត្រូវបានអគ្គនាយកសណ្ឋាគារ Victoria Angkor Resort & spa តំណាងឱ្យក្រុមហ៊ុន Victoria Angkor Company Limited (VAK) ជួលមកអោយបំរើការងារក្នុងសណ្ឋាគារ តាមកិច្ចសន្យាការងារចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលចាប់ផ្តើមបំពេញការងារនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ ហើយនិងត្រូវបញ្ចប់កិច្ចសន្យាការងារនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ ប៉ុន្តែក្រោយមកនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ខណៈកិច្ចសន្យាការងារមុនមិនទាន់អស់សុពលភាពនៅឡើយ ស្រាប់តែឈ្មោះ [redacted] Albert Pronk ក្នុងនាមខ្លួនជានិយោជិកបានតាក់តែងកិច្ចសន្យាការងារថ្មីមួយទៀតដែលបញ្ជាក់ថា (កិច្ចសន្យាការងារកែតម្រូវ) ដោយកិច្ចសន្យាការងារកែតម្រូវនឹងត្រូវបញ្ចប់នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ ជាមួយនិងការតំឡើងឋានៈតួនាទីជាអគ្គនាយករងសណ្ឋាគារ និងទទួលបានប្រាក់ខែគោល៣,000(បីពាន់) ដុល្លារអាមេរិក ក្នុងមួយខែ។ កិច្ចសន្យាការងារកែតម្រូវនេះមានភាពមិនប្រក្រតី និងមិនស្របតាមច្បាប់ឡើយ ហើយក៏បានបង្ហាញនូវអំពើរបស់ឈ្មោះ [redacted] Albert Pronk និងគូកន សុំដោយទុច្ចរិតឱ្យរាជការសាធារណៈនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ (មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប) ចេញនូវឯកសារសម្រាប់ធ្វើការកត់សម្គាល់សិទ្ធិអត្តសញ្ញាណ ឬឋានៈ ឬយល់ព្រមផ្តល់ការអនុញ្ញាតដោយមិនមានហត្ថលេខារបស់ភាគីនិយោជក (តំណាងក្រុមហ៊ុន) និងហត្ថលេខាដឹងឮដោយអ្នកគ្រប់គ្រងធនធានមនុស្សរបស់សណ្ឋាគារឡើយ។

**នាពេលសវនាការ**

-តាមអំណានពាក្យបណ្តឹង ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុងដេរ [redacted] Gontier)បានឆ្លើយថា: ឈ្មោះ [redacted] Albert Pronk ធ្លាប់ត្រូវបានអគ្គនាយកសណ្ឋាគារ Victoria Angkor Resort & Spa តំណាងឱ្យក្រុមហ៊ុន Victoria Angkor Company Limited (VAK) ជួលមកឱ្យបម្រើការងារក្នុងសណ្ឋាគារ តាមកិច្ចសន្យាការងារចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ ហើយនឹងត្រូវបញ្ចប់កិច្ចសន្យាការងារនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧។ ប៉ុន្តែក្រោយមកនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ខណៈកិច្ចសន្យាការងារមុនមិនទាន់អស់សុពលភាពនៅឡើយ ស្រាប់តែឈ្មោះ [redacted] Albert Pronk ក្នុងនាមខ្លួនជានិយោជិតបានតាក់តែងកិច្ចសន្យាការងារថ្មីមួយទៀតដែលបញ្ជាក់ថា "កិច្ចសន្យាការងារកែតម្រូវ"ដែលកិច្ចសន្យាការងារតាក់តែងថ្មីនេះនឹងត្រូវបញ្ចប់នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ជាមួយនឹងការដំឡើងឋានៈតួនាទីជាអគ្គនាយករងសណ្ឋាគារ នឹងទទួលបានប្រាក់ខែគោលចំនួន៣000(បីពាន់)ដុល្លារអាមេរិកក្នុងមួយខែ។កិច្ចសន្យាការងារកែតម្រូវ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] Albert Pronk ក្នុងនាមខ្លួនជានិយោជិតនោះ គឺមានតែហត្ថលេខាភាគីនិយោជិតខ្លួនឯងប៉ុណ្ណោះ មិនមានហត្ថលេខារបស់ភាគីនិយោជក (តំណាង

ក្រុមហ៊ុន) នឹងហត្ថលេខាដឹងឮដោយអ្នកគ្រប់គ្រងធនធានមនុស្សរបស់សណ្ឋាគារអ្វីឡើយ ប៉ុន្តែកិច្ចសន្យាការងាររបៀបឯកតោភាគី (មានតែភាគីនិយោជិត) នេះបែរជាទទួលបានការបញ្ជាក់ការអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសលេខOTA002442កប ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧ ឈ្មោះ [redacted] Albert Pronk បម្រើការងារក្នុងសហគ្រាសគ្រឹះស្ថានសណ្ឋាគារ Victoria Angkor Resort & Spa ចេញដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ទៅវិញ។ សំណូមពរៈ សូមឱ្យមានការផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ ប៉ាទ្រិក អាល់ប៊ឺតប្រុន ([redacted] Albert Pronk) តាមនីតិវិធីនៃច្បាប់ពីបទសុំឱ្យផ្តល់ឯកសារដោយទុច្ចរិត, សូមឱ្យមានការដាក់បម្រាមលើការធ្វើដំណើរចេញចូលក្រៅប្រទេសពីដែនដីនៃព្រះរាជាណាចក្រកម្ពុជារបស់ឈ្មោះ [redacted] អាល់ប៊ឺតប្រុន ([redacted] Albert Pronk) និងសូមទាមទារសំណងការខូចខាតទឹកប្រាក់របស់ក្រុមហ៊ុនរយៈពេល១០(ដប់)ខែ ចំនួន១២០.០០០.០០០(មួយរយម្ភៃលាន)រៀល និងជំងឺចិត្ត ព្រមទាំងសេវាផ្លូវច្បាប់ពីឈ្មោះ [redacted] អាល់ប៊ឺតប្រុន [redacted] Albert Pronk)ស្មើនឹងទឹកប្រាក់ចំនួន៦០.០០០.០០០(ហុកសិបលាន)រៀល។

-តាមអំណានកិច្ចសន្យាការងារ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ រវាងសណ្ឋាគារវិចតូរីយ៉ាអង្គរ និងឈ្មោះ [redacted] អាល់ប៊ឺតប្រុង ថាៈ បានព្រមព្រៀង ចុះកិច្ចសន្យាការងារ ដែលចាប់ផ្តើមពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ បញ្ចប់នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ ដោយផ្តល់ឋានៈអោយជនជាប់ចោទជាប្រធានម្ហូបអាហារ និងភេសជ្ជៈ ទទួលប្រាក់ខែ២៥០០(ពីរពាន់ប្រាំរយ)ដុល្លារអាមេរិក។

-តាមអំណានកិច្ចសន្យាការងារកែតម្រូវ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ រវាងសណ្ឋាគារវិចតូរីយ៉ាអង្គរ និងឈ្មោះ [redacted] អាល់ប៊ឺតប្រុង ថាៈ បានព្រមព្រៀង ចុះកិច្ចសន្យាការងារ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ និងបន្ត លើកលែងតែការបញ្ចប់កិច្ចសន្យា រយៈពេល១២(ដប់ពីរ)ខែដែលនឹងបញ្ចប់ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ ដោយផ្តល់ឋានៈអោយជនជាប់ចោទជាអគ្គនាយករង របស់សណ្ឋាគារ ហើយទទួលប្រាក់ខែ៣០០០(បីពាន់)ដុល្លារអាមេរិក ចាប់ផ្តើមពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧។

<u>**សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ និងតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី**</u>

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] Gontier បានធ្វើសេចក្តីសន្និដ្ឋានថាៈខ្លួនសូមរក្សាខ្លឹមសារនៃពាក្យសុំផ្តល់សេចក្តីសន្និដ្ឋានការពារចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ ខ្លួនបានដាក់អោយជូនតុលាការរួចហើយ ប៉ុន្តែសូមធ្វើការកែតម្រូវនៅត្រង់ចំណុច២ នៃសំណូមពររបស់ខ្លួនដែលបញ្ជាក់អំពីការទាមទារសំណងការខូចខាតរបស់ក្រុមហ៊ុនពីរទឹកប្រាក់ ១២០.០០០.០០០ លានរៀល មកចំនួន ៣០.០០០.០០០ លានរៀលវិញ ដោយការទាមទារសំណងជម្ងឺចិត្តព្រមទាំងសេវាផ្លូវច្បាប់នូវរក្សាដដែល។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ឃើញថាមានភស្តុតាងគ្រប់គ្រាន់ ហេតុនេះ តំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរដដែល។

-ក្រោយពីបានស្តាប់អំណានពាក្យបណ្តឹងរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យភស្តុតាងនិងពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ថិតនៅខេត្តសៀមរាប ពិតជាមានករណីសុំផ្តល់ឯកសារដោយទុច្ចរិត ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] អាល់ប៊ឺតប្រុន ([redacted] Albert Pronk) ប្រាកដមែន។

២-តាមពាក្យបណ្តឹង និងភស្តុតាងនានាក្នុងសំណុំរឿងអាចអោយតុលាការកំណត់បានថាជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសៈ **សុំផ្តល់ឯកសារដោយទុច្ចរិត** ដូចការចោទប្រកាន់ ដោយហេតុថា ជនជាប់ចោទបានចុះកិច្ចសន្យាការងារ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ម្តងរួចហើយតែមិនបានកញ្ចប់ផង ក៏បានបង្កើតកិច្ចសន្យាកែតម្រូវមួយទៀត ដោយពុំមានការយល់ព្រមពីភាគីជនរងគ្រោះ ហើយតម្លើងឋានៈខ្លួន ទៅជាអគ្គនាយករងសណ្ឋាគារ និងទទួលប្រាក់ខែរហូតដល់៣.០០០(បីពាន់)ដុល្លារអាមេរិក ក្នុង១ខែ និងមានការចុះហត្ថលេខាពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

៣-សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការបន្លំឯកសារឱ្យរាជការសាធារណៈចេញ នូវឯកសារសម្រាប់ធ្វើការកត់សម្គាល់សិទ្ធិអត្តសញ្ញាណ ឬឋានៈ ឬយល់ព្រមផ្តល់ការអនុញ្ញាត ដើម្បីបានជាប្រយោជន៍របស់ខ្លួន ដែលច្បាប់បញ្ញត្តិថាជាបទល្មើស និងផ្តន្ទាទោស។

៤-អំពើរបស់ជនជាប់ចោទបានប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម។

៥-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ។

៦-មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទៈឈ្មោះ [redacted] Albert Pronk ភេទប្រុស អាយុ៦៤ឆ្នាំ ជនជាតិហូឡង់ ពីបទៈ សុំផ្តល់ឯកសារដោយទុច្ចរិត ប្រព្រឹត្តនៅខេត្តសៀមរាប កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៦៣២ នៃក្រមព្រហ្មទណ្ឌ។

៧-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ និងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] កុងជេរ ([redacted] Gontier) បានធ្វើសេចក្តីសន្និដ្ឋានថា: ខ្លួនសូមរក្សាខ្លឹមសារនៃពាក្យសុំផ្តល់សេចក្តីសន្និដ្ឋានការពារ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់ខ្លួនដដែល បានដាក់អោយជូនតុលាការរួចហើយ ប៉ុន្តែសូមធ្វើការកែតម្រូវនៅត្រង់ចំណុច២ នៃសំណូមពររបស់ខ្លួនដែលបញ្ជាក់អំពីការទាមទារសំណងការខូចខាតរបស់ក្រុមហ៊ុនពីរទឹកប្រាក់ ១២០.០០០.០០០ (មួយ រយម្ភៃលាន) រៀល មកចំនួន ៣០.០០០.០០០ (សាមសិបលាន) រៀលវិញ ដោយការទាមទារសំណងជម្ងឺចិត្តព្រមទាំងសេវាផ្លូវច្បាប់នូវរក្សាដដែល គប្បីតុលាការលើកមកពិចារណា។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោស:ឈ្មោះ [redacted] Albert Pronk ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិហូឡង់ ដាក់ពន្ធនាគារកំណត់១៨(ដប់ប្រាំបី)ខែ និងពិន័យជាប្រាក់ចំនួន៣.០០០.០០០ (បីលាន) រៀល។

ពីបទ: **សុំផ្តល់ឯកសារដោយទុច្ចរិត** ប្រព្រឹត្តនៅខេត្តសៀមរាប កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៦៣២ នៃក្រមព្រហ្មទណ្ឌ។

២-អោយឈ្មោះ [redacted] Albert Pronk សំណងការខូចខាត ចំនួន៣០.០០០.០០០ (សាមសិបលាន)រៀល និងជម្ងឺចិត្តសងចំនួន២០.០០០.០០០ (ម្ភៃលាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] កុងជេរ ([redacted] Gontier) ច្រានចោលការទាមទារលើសពីនេះ។

សាលក្រមនេះជំនុំជម្រះជាសាធារណ:នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ កំបាំងមុខជនជាប់ចោទ,ចំពោះមុខមេធាវីការពារនិងតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណ:នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា** [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃអង្គារ ១០កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅសៀមរាប ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner